ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

លេខ ០៥៦ សណន.កសក


# សេចក្តីណែនាំ
# ស្តីពី
# វិធានការការពារនិងទប់ស្កាត់ភ្លើងឆេះព្រៃ

ជារៀងរាល់ឆ្នាំ ធាតុអាកាសទូទៅនៅក្នុងព្រះរាជាណាចក្រកម្ពុជាចាប់ផ្តើមផ្លាស់ប្តូរពីរដូវវស្សា ចូលដល់រដូវរំហើយ ហើយបន្តចូលរដូវប្រាំងដែលធាតុអាកាសមានសភាពក្តៅហែង ស្ងួតខ្លាំង ជាកត្តាងាយបង្កនូវភ្លើងឆេះព្រៃ។ ក្រៅពីបាតុភូតធម្មជាតិដែលអាចបង្កឲ្យមានភ្លើងឆេះព្រៃ ប្រការដែលគួរឲ្យព្រួយបារម្ភបំផុតនោះគឺភ្លើងឆេះព្រៃដែលបង្កឡើងដោយសារសកម្មភាពរបស់មនុស្សផ្ទាល់។ កត្តាចម្បងដែលបង្កឲ្យមានភ្លើងឆេះព្រៃញឹកញាប់បំផុតនារដូវប្រាំង តាមរយៈសកម្មភាពមានជាអាទិ៍ៈ ការកាប់ឆ្ការដុតរានព្រៃដើម្បីដាំដំណាំកសិកម្មផ្សេងៗ ការធ្វើកសិកម្មពនេចរ ការតាំងទីលំនៅដ្ឋានថ្មី ការដុតព្រៃដើម្បីចាប់សត្វ ការបន្សល់ដើមភ្លើងនៅក្នុងព្រៃតាមរយៈការធ្វេសប្រហែសរបស់មនុស្ស។ល។

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានកត់សម្គាល់ឃើញថា ភ្លើងឆេះព្រៃជារៀងរាល់ឆ្នាំបានបង្កឲ្យមានបញ្ហាដ៏ធ្ងន់ធ្ងរដល់ការបាត់បង់ធនធានព្រៃឈើ និងព្រៃលិចទឹក ហើយបានបង្កវិនាសកម្ម និងការខាតបង់យ៉ាងធ្ងន់ធ្ងរដល់សង្គមសេដ្ឋកិច្ចជនបទ សេដ្ឋកិច្ចជាតិ ធនធានធម្មជាតិ និងបរិស្ថាន។

ដោយសង្កេតឃើញបញ្ហាប្រឈមទាំងនេះ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ សូមធ្វើការណែនាំដល់មន្ត្រីរដ្ឋបាលព្រៃឈើ និងរដ្ឋបាលជលផល ដើម្បីអនុវត្តវិធានការណ៍ដូចខាងក្រោម ៖

១-ទប់ស្កាត់ការប្រើប្រាស់ភ្លើងជាមធ្យោបាយដើម្បីយកឃ្មុំ ការដុតស្វាក់ចាប់សត្វ និងការដុតវាលស្មៅដើម្បីយកល្បាស់ធ្វើចំណីសត្វពាហនៈ។

២-ទប់ស្កាត់ការកាប់ឆ្ការ គាស់រាន ឈូសឆាយ ដុតព្រៃឈើ និងព្រៃលិចទឹក ដើម្បីពង្រីកផ្ទៃដីដំណាំកសិកម្ម ឬក្នុងគោលបំណងផ្សេងៗទៀតដែលជាសកម្មភាពល្មើសច្បាប់ និងនាំមកនូវភ្លើងឆេះព្រៃឈើ និងព្រៃលិចទឹក។

៣-ក្នុងករណីចាំបាច់ដែលត្រូវប្រើភ្លើងជាមធ្យោបាយក្នុងការដុតកាកសំណល់ឈើព្រៃ ក្រោមគោលបំណងដាំដំណាំកសិកម្ម និងសកម្មភាពស្របច្បាប់ផ្សេងទៀត ត្រូវជូនដំណឹងដល់សង្កាត់រដ្ឋបាលព្រៃឈើ ឬសង្កាត់រដ្ឋបាលជលផលសាមី ដើម្បីណែនាំអនុវត្តវិធានការបច្ចេកទេសសមស្របដែលអាចធានាសុវត្ថិភាពចំពោះភ្លើងព្រៃ។

៤-ការរុករកផល អនុផលព្រៃឈើជាប្រពៃណី និងសកម្មភាពផ្សេងទៀតដែលចំបាច់ត្រូវប្រើភ្លើងជាមធ្យោបាយ (ដុតរណ្តៅជ័រ) ត្រូវណែនាំពន្លត់ភ្លើងឲ្យអស់ជាចាំបាច់មុនពេលចាកចេញពីដើមឈើច្បោះជ័រ ឬទីតាំងដែលប្រើភ្លើងនោះ។

៥-ក្នុងករណីកើតមានភ្លើងឆេះព្រៃ ត្រូវប្រញាប់ចាត់វិធានការទប់ស្កាត់ជាបន្ទាន់តាមរយៈការប្រកាសអាសន្ន និងស្នើអភិបាលនៃគណៈអភិបាលខេត្ត ជាប្រធានអនុគណៈកម្មាធិការខេត្តដើម្បីទប់ស្កាត់លុបបំបាត់ និងបង្ក្រាបការកាប់រានដុតឈូសឆាយ និងហ៊ុមព័ទ្ធដីព្រៃឈើធ្វើជាកម្មសិទ្ធិទទួលដឹកនាំបញ្ជាផ្ទាល់ក្នុងការប្រើកម្លាំងសរុបរួមមានប្រជាពលរដ្ឋ សហគមន៍ សិស្សានុសិស្ស ព្រះសង្ឃ មន្ត្រីរាជការ កងកម្លាំងប្រដាប់អាវុធ។ល។ ដែលឈរជើងនៅក្នុង✓✗ មូលដ្ឋាននោះ ដើម្បីរួមគ្នាទប់ស្កាត់ និងពន្លត់ភ្លើងព្រៃឲ្យមានប្រសិទ្ធភាព។

៦-ក្រោមការដឹកនាំរបស់ប្រធានគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋថ្នាក់ខេត្ត រដ្ឋបាលព្រៃឈើ និងរដ្ឋបាលជលផល ត្រូវចាត់វិធានការតាមផ្លូវច្បាប់ចំពោះជនណាដែលបានកាប់រុករាន ដុតព្រៃ និងកាន់កាប់ដីព្រៃឈើដែលឆេះហើយដោយអនាធិបតេយ្យដែលផ្ទុយនឹងច្បាប់ និងប៉ះពាល់ដល់នយោបាយចាស់សកម្មភាពថ្មីលើវិស័យដីធ្លី និងបទបញ្ជានានារបស់រាជរដ្ឋាភិបាល។

៧-ត្រូវសហការជាមួយអាជ្ញាធរដែនដីក្នុងការហាមឃាត់ចូលប្រើប្រាស់ដីព្រៃឈើ និងព្រៃលិចទឹកដែលឆេះរួច ដើម្បីទុកលទ្ធភាពឲ្យរុក្ខជាតិដុះឡើងវិញតាមលក្ខណៈធម្មជាតិ។

អនុលោមតាមច្បាប់ស្តីពីព្រៃឈើ និងច្បាប់ស្តីពីជលផល ប្រជាពលរដ្ឋ កងកម្លាំងប្រដាប់អាវុធ និងអាជ្ញាធរដែនដីគ្រប់ថ្នាក់ ត្រូវមានករណីយកិច្ចទទួលខុសត្រូវថែរក្សា ការពារព្រៃឈើ បង្ការ និងប្រយុទ្ធនឹងភ្លើងឆេះព្រៃ ចូលរួមថែរក្សាជម្រកមច្ឆជាតិ ការពារបង្ការ និងប្រយុទ្ធនឹងភ្លើងឆេះព្រៃលិចទឹក នៅតាមមូលដ្ឋានរៀងៗខ្លួន។ ជនណាដែលបានប្រព្រឹត្ត ឬបង្កឲ្យមានភ្លើងឆេះព្រៃ ឬភ្លើងឆេះព្រៃលិចទឹកដោយចេតនា ត្រូវផ្តន្ទាទោសក្រោមបទល្មើសព្រៃឈើថ្នាក់ទី១ ឬបទល្មើសជលផលថ្នាក់ទី១ដែលត្រូវជាប់ពន្ធនាគារពី០៣ឆ្នាំទៅ០៥ឆ្នាំ ឬពី០៥ឆ្នាំទៅ១០ឆ្នាំ។

ទទួលបានសេចក្តីណែនាំនេះ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ មានជំនឿ និងទំនុកចិត្តចំពោះគ្រប់ស្ថាប័នមានសមត្ថកិច្ច រដ្ឋបាលថ្នាក់ក្រោមជាតិពាក់ព័ន្ធ មន្ត្រីរាជការ កងកម្លាំងប្រដាប់អាវុធ សហគមន៍ សិស្សានុសិស្ស ព្រះសង្ឃ និងប្រជាពលរដ្ឋទាំងអស់បានយល់ច្បាស់ពីករណីយកិច្ចក្នុងការការពារ ទប់ស្កាត់ និងប្រយុទ្ធនឹងភ្លើងឆេះព្រៃ ដោយរួមសហការយ៉ាងជិតស្និទ្ធជាមួយសមត្ថកិច្ចរដ្ឋបាលព្រៃឈើ និងរដ្ឋបាលជលផលក្នុងមូលដ្ឋានរៀងៗខ្លួន អនុវត្តតាមសេចក្តីណែនាំនេះប្រកបដោយប្រសិទ្ធភាពខ្ពស់ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២១ ខែមករា ឆ្នាំ២០១៦

**រដ្ឋមន្ត្រី**

**បណ្ឌិត វ៉េង សាខុន**

**កន្លែងទទួល:**

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-ទីស្តីការគណៈរដ្ឋមន្ត្រី
-ក្រសួងមហាផ្ទៃ
-ក្រសួងការពារជាតិ
-ក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្មនិងជនបទ
-គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ
-ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
-ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
-ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
-ក្រសួងបរិស្ថាន
-ក្រសួងធនធានទឹកនិងឧតុនិយម
-ក្រសួងយុត្តិធម៌
-សាលារាជធានី ខេត្ត
-អង្គភាពពាក់ព័ន្ធក្រោមឱវាទក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
-មន្ទីរកសិកម្មរាជធានី ខេត្ត
-ឯកសារ កាលប្បវត្តិ